# កូនទា រូបអាក្រក់

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C



កែសម្រួលដោយ TUKTUK

រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ Seinan Jo Gakuin ប្រទេសជប៉ុន



កាលពីព្រេងនាយ មានមេទាមួយក្បាលរស់នៅក្នុងកសិដ្ឋានមួយកន្លែងក្បែរមាត់ទឹក។ មេទាពងបានចំនួនប្រាំពីរគ្រាប់។ ជារៀងរាល់ថ្ងៃ វាតែងតែក្រាបពងរងចាំថ្ងៃកូនៗរបស់វាញាស់។





ទីបំផុតស៊ុតទាំងអស់នោះក៏ចាប់ផ្ដើមញាស់ម្ដងមួយៗ រហូតបានកូនទាចំនួនប្រាំមួយក្បាល។ កូនទាទាំងនោះសុទ្ធតែស្អាតៗមានរោមក្រាស់ហើយពណ៌លឿង។ កូនទាទាំងអស់ស្រែក «កាបៗ! កាបៗ! កាបៗ!» នៅសល់តែស៊ុតមួយដែលមិនទាន់ញាស់ដោយសារស៊ុតនោះធំចម្លែកខុសពីគេ។





ម្ដាយរបស់វាក៏សម្រេចចិត្តក្រាបពងម្ដងទៀត។
នៅថ្ងៃបន្ទាប់ ស៊ុតនោះក៏បានញាស់ចេញ។ កូនទាមានរូបរាងអាក្រក់ខុសគេ
វាមានមាឌធំ ពណ៌ប្រផេះមិនដូចកូនទាដទៃទៀតសោះ។ ម្ដាយរបស់វាមានការភ្ញាក់ផ្អើល
យ៉ាងខ្លាំងនិងពិបាកចិត្ត។ ម្ដាយរបស់វាបានគិតថា ពេលកូនទាធំឡើង វានឹងប្រែរូបរាង
ដូចជាបងៗរបស់វាវិញជាក់ជាមិនខាន។





ជាច្រើនថ្ងៃកន្លងផុតទៅ កូនទានៅតែមានរូបរាងអាក្រក់ដដែល។
បងៗរបស់វាលេងទឹកបឹងយ៉ាងសប្បាយរីករាយ ប៉ុន្តែពួកគេមិនចូលចិត្តលេងជាមួយវានោះទេ ថែមទាំងសើចចំអកឱ្យវាទៀតផង។
«កាបៗ! កាបៗ! កាបៗ! ចេញឱ្យឆ្ងាយទៅ ពួកយើងមិនចង់លេងជាមួយឯងនោះទេ!
ឯងជាកូនទាមានរូបរាងអាក្រក់ចម្លែកខុសគេ!»





កូនទារូបអាក្រក់ដើរបណ្តើរ យំបណ្តើរ ហើយបានងើយមើលទៅលើមេឃ ឃើញ សត្វបក្សីពណ៌សដ៏សែនស្រស់ស្អាត។ វាមានអារម្មណ៍ថា វាចង់ក្លាយជាសត្វបក្សី ស្អាតដូចគេដែរ។





កូនទារូបអាក្រក់ពិបាកចិត្តយ៉ាងខ្លាំង។ វាបានដើរទៅកាន់មាត់បឹងឆ្លុះមើលរូបរាងខ្លួនឯង។ កូនទារូបអាក្រក់គិតក្នុងចិត្តថា «ខ្ញុំពិតជាមានរូបរាងអាក្រក់ខុសពីគេពិតមែន គ្មាននរណាដូចខ្ញុំនោះទេ»។





កូនទារូបអាក្រក់បានសម្រេចចិត្តចាកចេញពីគ្រួសារ ដើរត្រាច់ចរតែម្នាក់ឯងក្នុងព្រៃជ្រៅ។
មិនយូរមិនឆាប់រដូវរងារបានមកដល់ វារងាញញ័រ គ្មានចំណីស៊ីតែ
ម្នាក់ឯងកណ្តាលព្រៃនោះ។





ភ្លាមៗនោះ កូនទារូបអាក្រក់បានជួបនឹងមេមាន់ ហើយនិយាយ «មេមាន់អើយ តើខ្ញុំអាចសុំជ្រកក្នុងផ្ទះជាមួយឯងបានដែរឬទេ?» ចំណែកឯមេមាន់តបទៅវិញ «ឆាប់ចេញឱ្យឆ្ងាយទៅកូនទារូបអាក្រក់ ឯងមិនស្អាតទេ»។ មេមាន់និងកូនមាន់ទាំងអស់នោះក៏បានដេញចឹកវា រហូតដល់វារត់ចេញទៅ។





កូនទារូបអាក្រក់បានជួបនឹងសត្វឆ្កែ វាមិនបានភ័យនោះទេ។
សត្វឆ្កែព្រុស ហើយហិតក្លិនវាបន្តិច រួចក៏បានដើរចេញទៅ។
កូនទារូបអាក្រក់បានគិតថា «ខ្ញុំពិតជាមានរូបរាងអាក្រក់ណាស់ហើយមើលទៅ
សូម្បីតែសត្វឆ្កែក៏វាមិនស៊ីខ្ញុំដែរ»។





កូនទារូបអាក្រក់បានបន្តដំណើរទៅមុខទៀត ហើយបានជួបនឹងកសិករម្នាក់។ កសិករនោះបានយកវាទៅផ្ទះឱ្យប្រពន្ធនិងកូនៗរបស់គាត់ចិញ្ចឹម។នៅទីនោះវាមានបញ្ហាជាមួយនឹងសត្វឆ្មា។ សត្វឆ្មាបានសើចចំអកឱ្យវាថា « ម៉េវ! ឯងជាកូនទារូបរាងអាក្រក់ ខ្ញុំមិនចង់រស់នៅជាមួយឯងនោះទេ»។កូនទារូបអាក្រក់ក៏បានចាកចេញពីផ្ទះកសិករនោះ និងបន្តដំណើរត្រាច់ចរក្នុងព្រៃជ្រៅម្តងទៀត។





វាដើរហើយ ដើរទៀតរហូតដល់និទាឃរដូវមកដល់ អ្វីៗបានផ្លាស់ប្តូរ
រុក្ខជាតិប្រែជាលាស់ខៀវខ្ចីម្តងទៀត។ កូនទារូបអាក្រក់បានជួបនឹងហ្វូងសត្វបក្សីពណ៌ស
ដែលកំពុងហែលលេងក្នុងទឹក។ វាមានអារម្មណ៍ថា សប្បាយរីករាយ ហើយបានដើរទៅក្បែរ
មាត់ទឹកនោះឱនក្បាលចុះក្រោម។
រំពេចនោះ...





វាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលឃើញរូបរាងថ្មីរបស់វា។
វាបានបែរមុខចេញ ស្រាប់តែស្រមោលនៅក្នុងទឹកក៏បានបែរចេញព្រមគ្នាដែរ។
ភ្លាមៗនោះ កូនទារូបអាក្រក់បានក្លាយជាបក្សីពណ៌សដ៏ស្រស់ស្អាត ដែលវាធ្លាប់ឃើញ
ពីមុននៅលើមេឃ។ វាសប្បាយចិត្តខ្លាំងណាស់។





ក្រោយពីហ្វូងសត្វបក្សីពណ៌សលេងទឹករួច ក៏បានហើរទៅលើមេឃព្រមគ្នា។
មានសត្វបក្សីពណ៌សមួយក្បាលបានប្រាប់វា «ឯងអាចមករស់នៅជាមួយពួកយើង
ទាំងអស់គ្នាបាន»។វាក៏បានហោះហើរទៅលើមេឃជាមួយសត្វបក្សីពណ៌សទាំងអស់
នោះដោយក្តីរីករាយ។






# កូនទារូបអាក្រក់

គំនូរជីវចល

ធនធានបង្រៀន

កែសម្រួលដោយ TUKTUK

រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ
Seinan Jo Gakuin ប្រទេសជប៉ុន

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary